ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ១៤-០២៣-០២៥ ប្រកាសព័ត៌មាន

ថ្ងៃចន្ទ ៨រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុន UnionPay International ស្តីពី "កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនតាមយូអរកូដ"

នៅរសៀលថ្ងៃចន្ទ ៨រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយក្រុមហ៊ុន UnionPay International ស្តីពី "កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនតាមយូអរកូដ" នៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ បណ្ឌិត ជា សិរី ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ដើម្បីជំរុញនវានុវត្តន៍ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ លើការប្រើប្រាស់សេវាធនាគារនិងហិរញ្ញវត្ថុ ប្រកបដោយជំនឿទុកចិត្ត សុវត្ថិភាព ប្រសិទ្ធភាព ស្ថិរភាព និងបរិយាបន្ន សំដៅគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។

អនុស្សរណៈនៃការយោគយល់គ្នានេះ រៀបចំឡើងក្នុងគោលបំណងផ្តល់នូវក្របខ័ណ្ឌជាក់លាក់សម្រាប់កិច្ចសហប្រតិបត្តិការ ដើម្បីលើកកម្ពស់ដល់ប្រតិបត្តិការទូទាត់ឆ្លងប្រទេសរវាង KHQR នៃប្រព័ន្ធបាគងជាមួយនឹងបណ្តាញ QR Code របស់ក្រុមហ៊ុន UnionPay International។ គំនិតផ្តួចផ្តើមនេះ នឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់ប័ណ្ណទូទាត់ UPI ដែលមកទស្សនាប្រទេសកម្ពុជានឹងអាចប្រើប្រាស់សេវាទូទាត់របស់ UnionPay ដើម្បីស្កេន KHQR Code ដែលមានភ្ជាប់ជាមួយគណនីធនាគារជាប្រាក់រៀលក្នុងស្រុក សម្រាប់ធ្វើការទូទាត់នានា ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ទន្ទឹមនេះ ប្រជាជនកម្ពុជាដែលប្រើប្រាស់ប្រព័ន្ធបាគង និងមានគណនីធនាគារជាប្រាក់រៀល ក៏អាចធ្វើការស្កេន QR Code របស់ពាណិជ្ជករ UnionPay នៅក្នុងប្រទេសចិន និងទូទាំងពិភពលោកផងដែរ ការណ៍នេះនឹងរួមចំណែកយ៉ាងច្រើនក្នុងការជំរុញវិស័យទេសចរណ៍ និងសកម្មភាពពាណិជ្ជកម្មកាន់តែមានភាពងាយស្រួល និងតម្លៃសមរម្យ។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B14.023.025.PR

Phnom Penh, 10 July 2023

# Press Release
## on the Memorandum of Understanding (MoU) on "Cross Border QR Code Payment Cooperation" Between The National Bank of Cambodia and UnionPay International Co.,Ltd

On 10th, July 2023, the National Bank of Cambodia and UnionPay International signed a Memorandum of Understanding (MoU) on "Cross-Border QR Code Payment Cooperation" at the Center for Banking Studies, presided over by H.E. Dr. Chea Serey, Deputy Governor of the National Bank of Cambodia, to promote innovation and financial technology on the use of banking and financial services with confidence, security, efficiency, stability and environment to support the policies of the Royal Government of Cambodia in the development of the economy and digital society.

This MoU aims to promote efficient and secure cross-border QR Code payment transactions through KHQR between Bakong's network and UnionPay International's global QR Code acceptance network. This initiative will allow visiting UPI cardholders to scan KHQR Code of Cambodian merchants, that is connected to a Khmer Riel bank account and make payments, which will further promote the use of local currency. Bakong users with Khmer Riel bank accounts, will also be able to use local wallets and apps at UnionPay QR Code accepting merchants in China and globally, which will make a significant contribution to promoting more convenient and affordable tourism and business activities.

**CONTACT :**
Communication Office of National Bank of Cambodia
Phone Number : (855) 23 990 196
Email : nbccommunication@nbc.gov.kh
**Official Channels of the National Bank of Cambodia :**
www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA